**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្ដីការគណៈរដ្ឋមន្ត្រី**
**លេខ :** ០៥ ប្រកព

# សេចក្ដីប្រកាសព័ត៌មាន
# ស្ដីពី
# លទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី
# ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៩

នៅព្រឹកថ្ងៃសុក្រ ១កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៩ វេលាម៉ោង៨និង៣០នាទីព្រឹក នៅវិមានសន្តិភាព ទីស្ដីការគណៈរដ្ឋមន្ត្រី មានបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិនិត្យនិងពិភាក្សាលើៈ

**១-សេចក្ដីព្រាងច្បាប់ស្ដីពីសំណង់។**
**២-សេចក្ដីព្រាងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ២០២០-២០២២។**
**៣-សេចក្ដីព្រាងរបាយការណ៍ស្វ័យវាយតម្លៃស្ដីពីការត្រួតពិនិត្យឡើងវិញនៃការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ(អ៊ុនកាក់ ឬ UNCAC) ជុំទី២ នៅកម្ពុជា។**
**៤-បញ្ហាផ្សេងៗៈ**

សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំការអនុម័តយល់ព្រមពីស្ថាប័ននីតិប្បញ្ញត្តិលើៈ

៤.១.កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃតំបន់រដ្ឋបាលពិសេសហុងកុងនៃសាធារណរដ្ឋប្រជាមានិតចិន ស្ដីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល។

៤.២.ពិធីសារទី២ ស្ដីពីការកំណត់ច្រកទ្វារព្រំដែនឆ្លងកាត់ នៃកិច្ចព្រមព្រៀងក្របខណ្ឌអាស៊ានស្ដីពីកិច្ចសម្របសម្រួលការដឹកជញ្ជូនឆ្លងកាត់ទំនិញ។

ក្រោយពីបានស្ដាប់របាយការណ៍ និងមតិពិភាក្សាផ្លាស់ប្ដូរយោបល់រួចមក អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានសម្រេចអនុម័តៈ

## ១-សេចក្ដីព្រាងច្បាប់ស្ដីពីសំណង់

ស្ថិតក្នុងបរិការណ៍នៃសន្តិភាពនិងស្ថិរភាពនយោបាយ ព្រមទាំងសន្ទុះនៃការរីកចម្រើនរបស់វិស័យសំណង់ ក្នុងរយៈពេលជាងមួយទស្សវត្សរ៍ចុងក្រោយនេះ តម្រូវឱ្យការពង្រឹងការគ្រប់គ្រងរាល់ដំណើរការនិងប្រតិបត្តិការក្នុងវិស័យសំណង់និងអ្នកពាក់ព័ន្ធនឹងការងារសំណង់ កាន់តែមានភាពចាំបាច់ជាសារវ័ន្ត។ សំណង់កាន់តែធំ កាន់តែខ្ពស់ និងកាន់តែស្មុគ្រស្មាញ កាន់តែទាមទារឱ្យការអនុវត្តបានត្រឹមត្រូវតាមបទដ្ឋានគតិយុត្ត បច្ចេកវិទ្យា ស្តង់ដា និងបទប្បញ្ញត្តិបច្ចេកទេស ដើម្បីធានាភាពរឹងមាំ គុណភាព សោភណភាពនិងចីរភាពនៃសំណង់ រៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថលដើម្បីឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី៤ផង និងដើម្បីលើកតម្កើងអត្តសញ្ញាណជាតិនិងភាពសុខដុមរមនានៅក្នុងសង្គមផង។ ឆ្លើយតបនឹងតម្រូវការនេះ សេចក្ដីព្រាងច្បាប់ស្ដីពីសំណង់ ត្រូវបានរៀបចំឡើងដើម្បីអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤

របស់រាជរដ្ឋាភិបាល ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព កសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ និងគោលនយោបាយស្តីពីការរៀបចំទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។

សេចក្តីព្រាងច្បាប់ស្តីពីសំណង់ មានគោលបំណងនិងសារប្រយោជន៍ដូចជា៖ ទី១).-ពង្រឹងការគ្រប់គ្រងភាគីពាក់ព័ន្ធនឹងការប្រតិបត្តិការងារទាំងឡាយក្នុងវិស័យសំណង់ ដើម្បីធានាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងការពារផលប្រយោជន៍ម្ចាស់សំណង់ អ្នកប្រើប្រាស់ និងសាធារណជន ទី២).-ចូលរួមពង្រឹងការគ្រប់គ្រងនគរូបនីយកម្ម ដោយអភិវឌ្ឍទីក្រុងឱ្យមានសោភណភាព និងបរិស្ថានល្អសម្រាប់ការរស់នៅប្រកបដោយចីរភាព សំដៅលើកកម្ពស់សុខុមាលភាពសាធារណៈ ទី៣).-បង្កើនគណនេយ្យភាព និងប្រសិទ្ធភាពក្នុងការប្រកបការងារនិងការប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់ និង ទី៤).-បង្កើនការជឿទុកចិត្តរបស់វិនិយោគិននៅក្នុងវិស័យសំណង់ និងជំរុញទីផ្សារអចលនទ្រព្យប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ចនិងសង្គម។

សេចក្តីព្រាងច្បាប់ស្តីពីសំណង់ ត្រូវបានបែងចែកចេញជា២២ជំពូក និង១១១មាត្រា ដែលរួមមាន៖ ជំពូកទី១ បទប្បញ្ញត្តិទូទៅ ជំពូកទី២ សមត្ថកិច្ចគ្រប់គ្រង ជំពូកទី៣ គោលការណ៍ ជំពូកទី៤ បទប្បញ្ញត្តិបច្ចេកទេសសំណង់ ជំពូកទី៥ ការគ្រប់គ្រងអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ ជំពូកទី៦ ការគ្រប់គ្រងការប្រកបវិជ្ជាជីវៈនិងការប្រកបអាជីវកម្មក្នុងវិស័យសំណង់ ជំពូកទី៧ ការប្រើសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ និងមន្ទីរពិសោធន៍សំណង់ ជំពូកទី៨ លិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើ ជំពូកទី៩ ការគ្រប់គ្រងគម្រោងប្លង់ ជំពូកទី១០ ការគ្រប់គ្រងការងារសាងសង់ឬរុះរើ ជំពូកទី១១ ការប្រើប្រាស់សំណង់ ជំពូកទី១២ សំណង់ដែលមានសភាពគ្រោះថ្នាក់ ជំពូកទី១៣ សំណង់ដែលសាងសង់ឬរុះរើដោយគ្មានឬខុសពីលិខិតអនុញ្ញាត ជំពូកទី១៤ អធិការកិច្ចសំណង់ ជំពូកទី១៥ វិសមិតភាព ជំពូកទី១៦ កិច្ចសន្យាម៉ៅការសាងសង់ឬរុះរើ ជំពូកទី១៧ ការធានារ៉ាប់រង ជំពូកទី១៨ ការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធនឹងសំណង់ ជំពូកទី១៩ ការដោះស្រាយវិវាទក្នុងវិស័យសំណង់ ជំពូកទី២០ ទោសប្បញ្ញត្តិ ជំពូកទី២១ អន្តរប្បញ្ញត្តិ ជំពូកទី២២ អវសានប្បញ្ញត្តិ និងឧបសម្ព័ន្ធ។

## ២-សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ២០២០-២០២២

សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ(ក.វ.ស.)៣ឆ្នាំរំកិល ២០២០-២០២២ មានគោលបំណងបង្ហាញពីទិន្នន័យគម្រោងវិនិយោគដែលមានអាទិភាពខ្ពស់របស់ក្រសួងស្ថាប័ន ដែលជាគោលនយោបាយមានចែងក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលនីតិកាលទី៦នៃរដ្ឋសភា និងជាផែនទីចង្អុលផ្លូវសម្រាប់ការអនុវត្តគោលនយោបាយដែលមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ២០១៩-២០២៣។

សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ(ក.វ.ស.)៣ឆ្នាំរំកិល ២០២០-២០២២ បានដាក់បញ្ចូលគ្នានូវគម្រោងកំពុងដំណើរការ ដែលការអនុវត្តគម្រោងកំពុងបន្តនៅក្នុងដំណាក់កាល ក.វ.ស. និងគម្រោងសម្រាប់អនុវត្ត ផ.យ.អ.ជ. ដែលជាគម្រោងស្នើសុំថ្មីត្រូវអនុវត្តក្នុងដំណាក់កាល ក.វ.ស.។ ក្នុងចំនួនគម្រោងសរុបទាំង៦០៩គម្រោងនៃសេចក្តីព្រាង ក.វ.ស. ៣ឆ្នាំរំកិល ២០២០-២០២២ នេះ មានចំនួន១៧១គម្រោងជាគម្រោងកំពុងដំណើរការ និងចំនួន៤៣៨គម្រោងជាគម្រោងសម្រាប់អនុវត្ត ផ.យ.អ.ជ.។

ការវិភាជទុនដល់គម្រោងនានារបស់ ក.វ.ស. ៣ឆ្នាំរំកិល ២០២០-២០២២ ទៅតាមវិស័យត្រូវបានកំណត់នៅក្នុង ផ.យ.អ.ជ. ២០១៩-២០២៣ ដែលរួមមាន៖ ៦,៥%សម្រាប់អនុវត្តគម្រោងក្នុងវិស័យសង្គមកិច្ច ៣២,៧%សម្រាប់អនុវត្តគម្រោងក្នុងវិស័យសេដ្ឋកិច្ច ៥៣,៨%សម្រាប់អនុវត្តគម្រោងក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ និង ៧,០%សម្រាប់អនុវត្តគម្រោងក្នុងវិស័យសេវានិងកម្មវិធីអន្តរវិស័យ។

សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ(ក.វ.ស.)៣ឆ្នាំរំកិល ២០២០-២០២២ ត្រូវបានរៀបចំឡើងដោយចែកចេញជា៤ជំពូក គឺ៖ ជំពូកទី១ សេចក្តីផ្តើម ជំពូកទី២ ទស្សនវិស័យសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០២០-២០២២ ជំពូកទី៣ កម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ២០២០-២០២២ ជំពូកទី៤ សេចក្តីសន្និដ្ឋាន និងមានបញ្ជីតារាងចំនួន១២។

## ៣-សេចក្តីព្រាងរបាយការណ៍ស្វ័យវាយតម្លៃស្តីពីការត្រួតពិនិត្យឡើងវិញនៃការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ(អ៊ុនកាក់ ឬ UNCAC) ជុំទី២ នៅកម្ពុជា

សេចក្តីព្រាងរបាយការណ៍ស្វ័យវាយតម្លៃស្តីពីការត្រួតពិនិត្យឡើងវិញនៃការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ(អ៊ុនកាក់ ឬ UNCAC)ជុំទី២ នៅកម្ពុជា គឺជារបាយការណ៍ថ្នាក់ជាតិ ដែលត្រូវបានសម្របសម្រួលរៀបចំពីសំណាក់អង្គភាពប្រឆាំងអំពើពុករលួយ ដែលជាអង្គភាពបង្គោលទទួលការងារនេះ និងមានការចូលរួមពីសំណាក់គ្រប់ភាគីពាក់ព័ន្ធ ដោយឆ្លងកាត់នូវការឆ្លើយសំណួរប្រមាណ ២០០០សំណួរ ជុំវិញប្រធានបទ២សំខាន់របស់អ៊ុនកាក់ គឺជំពូកទី២ ស្តីពីវិធានការបង្ការទប់ស្កាត់អំពើពុករលួយ និងជំពូកទី៥ ស្តីពីការបញ្ជូនមកវិញនូវផលនៃបទល្មើស។

តាមរយៈសេចក្តីព្រាងរបាយការណ៍ស្វ័យវាយតម្លៃស្តីពីការត្រួតពិនិត្យឡើងវិញនៃការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ(អ៊ុនកាក់ ឬ UNCAC) ជុំទី២ នៅកម្ពុជា បានបង្ហាញឱ្យឃើញថា កាតព្វកិច្ចនិងស្តង់ដាជាច្រើនលើសលប់ដែលត្រូវបានកំណត់ក្នុងអ៊ុនកាក់ ត្រូវបានកម្ពុជាបំពេញនិងឆ្លើយតបបានរួចរាល់។ ក្រៅពីក្របខណ្ឌច្បាប់និងបទដ្ឋានគតិយុត្ត យុទ្ធសាស្ត្រ និងចក្ខុវិស័យដែលរាជរដ្ឋាភិបាលបានដាក់ចេញនិងអនុវត្ត និងដែលបានចូលជាធរមាន របាយការណ៍ក៏បានបង្ហាញពីកំណែទម្រង់រដ្ឋលើគ្រប់វិស័យ ដែលតម្រង់ទៅលើការពង្រឹងអភិបាលកិច្ចល្អ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងរដ្ឋបាលសាធារណៈឱ្យកាន់តែមានប្រសិទ្ធភាព កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ការធ្វើវិមជ្ឈការនិងវិសហមជ្ឈការ ក៏ដូចជាការដាក់ចេញនិងអនុវត្តនូវអភិក្រមទាំង៥របស់ សម្តេចតេជោនាយករដ្ឋមន្ត្រី រួមមាន ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់ ដែលជាប្រទីបបំភ្លឺផ្លូវ និងជាការចូលរួមចំណែកយ៉ាងសំខាន់បំផុតទៅដល់បុព្វហេតុរួមគឺការប្រយុទ្ធប្រឆាំងអំពើពុករលួយផងដែរ។

## ៤-បញ្ហាផ្សេងៗ៖

៤.១. អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានអនុម័តបញ្ជូន ១).-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃតំបន់រដ្ឋបាលពិសេសហុងកុងនៃសាធារណរដ្ឋប្រជាមានិតចិន ស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគេចវេសបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និង ២).-ពិធីសារទី២ ស្តីពីការកំណត់ច្រកទ្វារព្រំដែនឆ្លងកាត់ នៃកិច្ចព្រមព្រៀងក្របខណ្ឌអាស៊ានស្តីពីកិច្ចសម្របសម្រួលការដឹកជញ្ជូនឆ្លងកាត់ទំនិញ ទៅសុំការអនុម័តយល់ព្រមពីស្ថាប័ននីតិប្បញ្ញត្តិ។

៤.២. សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានប្រកាសយល់ព្រមទទួលការភ្នាល់ជាមួយ សម រង្ស៊ី ដោយសម្តេចបានមានប្រសាសន៍ថា *«ខ្ញុំយល់ព្រមទទួលការភ្នាល់ជាមួយអាម្បៀ រង្ស៊ី ប្រសិនបើអ្នកឯងជាន់ទឹកដីខ្មែរនៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០១៩ ហើយខ្ញុំចាប់អ្នកឯងមិនបានក្នុងរយៈពេល២៤ម៉ោង ខ្ញុំនឹងសុខចិត្តចុះចេញពីតំណែង។ ប៉ុន្តែបើខ្ញុំចាប់ខ្លួនអ្នកឯងបានវិញ អ្នកឯងនឹងត្រូវបញ្ចប់ជីវិតនយោបាយ ព្រមទាំងរំលាយអង្គការចាត់តាំងទាំងឡាយណាដែលអ្នកឯងបានបង្កើតឡើង។ ផ្ទុយទៅវិញ ប្រសិនបើអ្នកឯងមិនហ៊ានចូលមកកម្ពុជាវិញទេ នោះអ្នកឯងនឹងត្រូវបញ្ចប់ជីវិតនយោបាយ និងរំលាយអង្គការចាត់តាំងដែលអ្នកឯងបង្កើត។ តើអ្នកឯងហ៊ាន ឬមិនហ៊ានចំពោះការភ្នាល់នេះ? ចំណុចមួយទៀតលើការស្បថ ប្រសិនបើអ្នកណាម្នាក់មិនគោរពលើការសន្យានៃការភ្នាល់នេះ ខ្ញុំសូមឱ្យវត្ថុស័ក្តិសិទ្ធិលើលោកផ្តាច់ជីវិតអ្នកដែលមិនគោរពការសន្យា និងក្រុមគ្រួសារទាំងពូជតែម្តង។ តើអ្នកឯងហ៊ានឬមិនហ៊ានចំពោះការភ្នាល់នេះ? ខ្ញុំសូមប្រជាពលរដ្ឋខ្មែរទូទាំងប្រទេសធ្វើជាសាក្សីចំពោះការភ្នាល់ និងសូមឱ្យ Fresh News ធ្វើជាអ្នកផ្សព្វផ្សាយលើការភ្នាល់នេះ»*។

៤.៣. សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី បានលើកឡើងថា៖

- ទាក់ទិននឹងបញ្ហាសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតកូរ៉េ គឺព្រះរាជាណាចក្រកម្ពុជាអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ចំពោះការដាក់ទណ្ឌកម្មលើសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតកូរ៉េ។
- រាជរដ្ឋាភិបាលនឹងបន្តជំរុញការអភិវឌ្ឍ ក្រុងព្រះសីហនុ ឱ្យទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង ដែលនឹងអាចក្លាយជាទីតាំងហិរញ្ញវត្ថុ នៅតាមឆ្នេរសមុទ្រកម្ពុជា ដោយផ្តល់អាទិភាពលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត រួមមានផ្លូវថ្នល់ និងប្រព័ន្ធលូជាដើម។

- រាល់អាជីវកម្មល្បែងភ្នាល់តាមម៉ាស៊ីនអេឡិចត្រូនិកតាមរយៈអ៊ីនធើណេតអនឡាញក្នុងនិងក្រៅប្រទេសគ្រប់ប្រភេទនិងគ្រប់រូបភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា គឺជាអំពើខុសច្បាប់ និងត្រូវបញ្ឈប់សកម្មភាពអាជីវកម្មទាំងនេះឱ្យអស់នៅដំណាច់ឆ្នាំ២០១៩នេះ។ សម្តេចតេជោ ក៏បានបញ្ជាក់ផងដែរថា ប្រទេសកម្ពុជាត្រូវអភិវឌ្ឍសេដ្ឋកិច្ចដោយឈរលើមូលដ្ឋាននៃសេវាទេសចរណ៍វប្បធម៌និងធម្មជាតិ ជាជាងការពឹងផ្អែកលើចំណូលពីអាជីវកម្មល្បែងភ្នាល់អនឡាញ។

- មិនឱ្យកងកម្លាំងប្រដាប់អាវុធទាំងអស់របស់កម្ពុជា ដែលរួមមានកងយោធពលខេមរភូមិន្ទ នគរបាល និងកងរាជអាវុធហត្ថ មានងារជា «ឧកញ៉ា» តទៅទៀតនោះឡើយ។ សម្តេចតេជោ បានបញ្ជាឱ្យកងកម្លាំងប្រដាប់អាវុធណាដែលមានងារជា «ឧកញ៉ា» ត្រូវសម្រេចចិត្តជាបន្ទាន់ ជ្រើសរើសយកតែមួយរវាងងារជា «ឧកញ៉ា» ឬតួនាទីក្នុងក្របខណ្ឌជាកងកម្លាំងប្រដាប់អាវុធ។

- រាជរដ្ឋាភិបាលនឹងបន្តពង្រឹងការធ្វើទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យាក្នុងការផ្តល់សេវាសាធារណៈ ដើម្បីជាផ្នែកមួយក្នុងការចូលរួមប្រយុទ្ធប្រឆាំងអំពើពុករលួយនៅកម្ពុជា។

- រាជរដ្ឋាភិបាលបានសម្រេចឱ្យរដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង បន្តផ្តល់សេវាដឹកជញ្ជូនដោយឥតគិតថ្លៃរយៈពេល២ឆ្នាំបន្ថែមទៀត ជូនដល់ព្រះសង្ឃ ចាស់ជរា ជនពិការ កុមារ សិស្ស និស្សិត និងកម្មករ កម្មការិនីទាំងអស់។

- ក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ ឆ្នាំកុរ ព.ស.២៥៦៣ នេះ រាជរដ្ឋាភិបាលបានសម្រេចបញ្ចេញរថយន្តក្រុង ដើម្បីដឹកជញ្ជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ ទៅស្រុកកំណើតនិងត្រលប់មករាជធានីភ្នំពេញវិញ។ នៅក្នុងឱកាសបុណ្យភ្ជុំបិណ្ឌនេះដែរ រាជរដ្ឋាភិបាលបានសម្រេចផ្តល់ប្រាក់ឧបត្ថម្ភចំនួន៥ម៉ឺនរៀលក្នុងម្នាក់ជូនដល់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ មន្ត្រីជាប់កិច្ចសន្យា បុគ្គលិកអណ្តែត និងមន្ត្រីចូលនិវត្តន៍។

អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានបិទសម័យប្រជុំនៅវេលាម៉ោង១២និង៥នាទី។

ថ្ងៃសុក្រ ១កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៩